# កិច្ចប្រជុំកំពូល ស្ថិតក្រោមការត្រួតត្រា

## ឯកសារគោលជំហរ
## ទៅលើកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារ ឆ្នាំ២០២១




ការបញ្ចុះបញ្ចូលពីសំណាក់ក្រុមហ៊ុនសាជីវកម្មដើម្បីការពារផលប្រយោជន៍កសិពាណិជ្ជកម្មបាន កំពុងជះឥទ្ធិពលទៅលើដំណើរការរៀបចំកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារ ដោយធ្វើឱ្យដំណើរការរៀបចំនេះ មិនមានតម្លាភាព និងផាត់ចេញនូវក្រុមប្រជាជន។ នៅក្នុងឯកសារនេះ ចលនាឡាវៀខែមប៉េះស៊ីណា ( La Via Campensina – LVC ) ពន្យល់ពីមូលហេតុដែលដំណើរការនេះ នឹងបង្កគ្រោះថ្នាក់ដល់អធិបតេយ្យស្បៀងរបស់ប្រជាជន និងការគម្រាមកំហែងដល់អនាគតភពផែនដី។

ឯកសារគោលជំហរនេះ រៀបរៀងដោយចលនាឡាវៀខែមប៉េះស៊ីណា ( LVC )
ខែធ្នូ ឆ្នាំ ២០២០

# សេចក្តីផ្តើម

មានការសង្ស័យបន្តិចបន្តួចទៅលើការលើកឡើងថាពិភពលោកត្រូវរួបរួមគ្នាដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរនិងផលប៉ះពាល់ដែលបន្តមានពីការរីករាលដាលនៃជម្ងឺកូវីដ-១៩ មកលើប្រព័ន្ធស្បៀងអាហាររបស់ពួកយើង។ ពិភពលោកមានការប្រែប្រួលនៅពេលដែលមានការប្រកាសឱ្យមានការរៀបចំកិច្ចប្រជុំកំពូល របស់អង្គការសហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារឆ្នាំ២០២១(UNFSS ២០២១) កាលពីខែធ្នូ ឆ្នាំ ២០១៩ ។ ទោះបីជាស្ថិតក្នុងស្ថានភាពដូច្នេះក្តី ការព្រួយបារម្ភកើតមានរួចទៅហើយទៅលើដំណើរការដែលគ្មានតម្លាភាព និងមិនមានភាពស្របច្បាប់ក្នុងការបង្កើត ការប្រកាស និងរៀបចំកិច្ចប្រជុំកំពូលនេះ។ ជាលទ្ធផល នៅខែមីនា ឆ្នាំ ២០២០ ចលនាឡាវៀខែមប៉េះស៊ីណា(LVC) ចូលរួមជាមួយចលនាសង្គម និងអង្គការសង្គមស៊ីវិលប្រមាណ៥៥០ ផ្សេងទៀតប្រឆាំងតវ៉ានឹងការត្រួតត្រាពីសំណាក់ក្រុមហ៊ុនសាជីវកម្មលើកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារមួយនេះ។

ដោយហេតុថាដំណើរការកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារនៅក្នុងឆ្នាំ២០២១ កាន់តែខិតជិតចូលមកដល់ សម្រាប់ចលនាឡាវៀខែមប៉េះស៊ីណា (LVC)ផ្ទាល់ ពួកយើងកាន់តែមានការព្រួយបារម្ភខ្លាំងឡើងៗ។ ទន្ទឹមនឹងនេះ ពួកយើងអះអាងថាកិច្ចសន្ទនាសកលស្តីពីប្រព័ន្ធស្បៀងអាហាររបស់ពួកយើង ជាកិច្ចការដ៏មានសារៈសំខាន់បំផុត ដោយហេតុថាជម្ងឺរាតត្បាតកូវីដ-១៩ បង្ហាញសារជាថ្មីម្តងទៀតពីភាពបរាជ័យនៃប្រព័ន្ធស្បៀងអាហាររបស់ក្រុមហ៊ុនសាជីវកម្ម ក្នុងការដោះស្រាយបញ្ហាភាពស្រេកឃ្លាន វិសមភាព និងវិបត្តិអេកូឡូស៊ី។

ឯកសារគោលជំហរនេះ បង្ហាញពីក្តីព្រួយបារម្ភ និងមតិយោបល់របស់ចលនាឡាវៀខែមប៉េះស៊ីណា(LVC) ទៅលើកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារនៅក្នុងឆ្នាំ ២០២១ ទាំងលើដំណើរការ និងមាតិកានៃកិច្ចប្រជុំ។ ឯកសារនេះ ក៏មានគោលបំណងបង្ហាញពីការចូលរួម និងការទាមទាររបស់ចលនាឡាវៀខែមប៉េះស៊ីណា(LVC) ស្តីពីការផ្លាស់ប្តូរប្រព័ន្ធស្បៀងអាហារចាំបាច់ដែលដឹកនាំដោយគោលការណ៍អធិបតេយ្យស្បៀង និងកសិអេកូឡូស៊ី។

សម្រាប់ចលនាឡាវៀខែមប៉េះស៊ីណា យើងមិនត្រឹមតែធ្វើការតស៊ូមតិប៉ុណ្ណោះទេ យើងក៏ចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើប្រជាធិបតេយ្យនីយកម្មក្នុងអង្គការសហប្រជាជាតិផងដែរ។ ចលនាឡាវៀខែមប៉េះស៊ីណា (LVC) មានតួនាទីយ៉ាងសំខាន់ក្នុងកំណែទម្រង់ដំណើរការគោលនយោបាយស្បៀងអាហាររបស់អង្គការសហប្រជាជាតិ បន្ទាប់ពីមានវិបត្តិស្បៀងអាហារកាលពីឆ្នាំ ២០០៨។ វិបត្តិនេះ ធ្វើឱ្យអង្គភាពអង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិកទទួលស្គាល់អំពីសារៈសំខាន់នៃការដាក់បញ្ចូលសម្លេងរបស់ចលនាប្រជាជនដែលរស់នៅតាមជនបទ និងសម្លេងរបស់សង្គមស៊ីវិលក្នុងការសម្រួចនូវគោលនយោបាយស្បៀងអាហារ។ ដោយឡែក អង្គការស្បៀងអាហារ និងកសិកម្ម(FAO) សម្រាប់ភាពជាដៃគូជាមួយនឹងអង្គការសង្គមស៊ីវិល និងកំណែទម្រង់នៃគណៈកម្មាធិការសន្តិសុខស្បៀងអាហារពិភពលោក(CFS) និងយន្តការសង្គមស៊ីវិល និងយន្តការរបស់ជនជាតិដើមភាគតិច(CSM) បានពាំនាំមកនូវគំរូគំនិត និងដំណើរការថ្មីដែលចាប់ផ្តើមត្រួសត្រាយផ្លូវឈានទៅរកប្រជាធិបតេយ្យនីយកម្មលើគោលនយោបាយប្រព័ន្ធស្បៀងអាហារសកលលោក។

1 http://www.fao.org/3/a-i3443e.pdf

កិច្ចការនេះ នាំឱ្យមានការផ្លាស់ប្តូរជាបណ្តើរៗនៃការកំណត់ថាជា "ទីលានប្រកួត" មិនមែនសម្រាប់តែសង្គមស៊ីវិលប៉ុណ្ណោះទេ ក៏ប៉ុន្តែសម្រាប់រដ្ឋាភិបាលនៃប្រជាជាតិនីមួយៗផងដែរ។ តាមរយៈការរួបរួមគ្នា និងការប្តេជ្ញារបស់គណៈកម្មាធិការផែនការអន្តរជាតិសម្រាប់អធិបតេយ្យស្បៀង (IPC) ចលនាឡាវៀខែមប៉េះស៊ីណា (LVC) បានដើរតួយ៉ាងសំខាន់នៅក្នុងការពង្រឹងសិទ្ធិអំណាចដល់ដំណើរការយន្តការសង្គមស៊ីវិល និងដំណើរការរបស់គណៈកម្មាធិការសន្តិសុខស្បៀងអាហារពិភពលោក។

តាមពិត មានការរីកចម្រើនជាច្រើនបានកើតចេញពីគោលការណ៍អធិបតេយ្យស្បៀង ដែលជាគំរូដ៏ទូលំទូលាយមួយសម្រាប់កែប្រែប្រព័ន្ធស្បៀងអាហារ និងស្តារឡើងវិញនូវសុខភាពមនុស្ស និងធម្មជាតិរបស់ពួកយើង ហើយដោយកើតចេញពីការគាំទ្រ និងតស៊ូមតិរបស់ចលនាឡាវៀខែមប៉េះស៊ីណា (LVC) ចាប់តាំងពីកិច្ចប្រជុំកំពូលស្តីពីស្បៀងអាហារពិភពលោកនៅក្នុងឆ្នាំ ១៩៩៦ មកម្ល៉េះ។ ដំណើរការរបស់ស្ថាប័នទាំងនេះ បានធ្វើឱ្យសម្រេចបាននូវសមិទ្ធផលគួរអោយកត់សម្គាល់មួយចំនួន ដោយក្នុងនោះរួមមានទាំងគោលការណ៍ណែនាំស្តីពីការកាន់កាប់ដីធ្លី គោលការណ៍ណែនាំស្តីពីការធានានិរន្តរភាពអ្នកនេសាទខ្នាតតូច ដំណើរការពាក់ព័ន្ធនឹងគោលការណ៍ណែនាំស្តីពីកសិកម្មគ្រួសារ បរិស្ថាន និងការបង្កើតថ្មីៗ និងយន្តការផ្សេងទៀតដែលកំពុងបន្តពិភាក្សា និងកាន់តែទូលាយជាងនេះទៅទៀតគឺសមិទ្ធផលស្តីពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិអ្នកស្រែ និងប្រជាជនផ្សេងទៀតដែលប្រកបរបរនៅតំបន់ជនបទ។ ឯកសារច្បាប់ទាំងនេះ បានបង្កជាឧបសគ្គដោយផ្ទាល់ដល់របៀបវារៈរបស់ក្រុមហ៊ុនសាជីវកម្មចម្រុះជាតិសាសន៍ ព្រមទាំងផ្តល់ឧបសគ្គដល់ការទាញយកផលប្រយោជន៍សេដ្ឋកិច្ចសកលលោកដោយក្រុមចក្រពត្តិ និងក្រុមអភិជន។

## ដំណើរឆ្ពោះទៅកិច្ចប្រជុំកំពូលមួយដែលមានលក្ខណៈផាត់ចេញ និងគ្រប់គ្រងដោយប្រទេសមហាអំណាចធំៗ និងស្ថាប័នហិរញ្ញវត្ថុ ក្រុមអភិជនក្នុងសកលលោក

តាមរយៈការប្រកាសនៅខែធ្នូ ឆ្នាំ២០១៩ កិច្ចប្រជុំកំពូលរបស់អង្គការ សហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារនៅក្នុងឆ្នាំ ២០២១ បានបង្ហាញពីគោលដៅក្នុងការពង្រីកផលប្រយោជន៍ជាអតិបរមាពីប្រព័ន្ធស្បៀងអាហារ ដោយដាក់គោលដៅផែនការសម្រេចអោយបានទាំងស្រុងនៅឆ្នាំ ២០៣០ ដោយសំដៅដោះស្រាយបញ្ហាប្រឈមពីបំរែបំរួលអាកាសធាតុ ធ្វើឱ្យប្រព័ន្ធស្បៀងអាហារមានការចូលរួម និងគាំទ្រសន្តិភាពដែលមាននិរន្តរភាព។




ក៏ប៉ុន្តែ ដំណើរការកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារនៅក្នុងឆ្នាំ ២០២១នេះ មានចរិកលក្ខណៈកើតចេញពីការចាប់ផ្តើមដោយមិនមានតម្លាភាព និងគ្មានការចូលរួម។ កាលពីពេលមុន អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) បានកោះប្រជុំកំពូលស្តីពីស្បៀងអាហារពិភពលោក (WFS) នៅឆ្នាំ ១៩៩៦ និង

ឆ្នាំ ២០០២ ដោយមានការសម្រេចចិត្តច្បាស់លាស់ពីសំណាក់រដ្ឋាភិបាលនានាជាសមាជិក។ កិច្ចប្រជុំកំពូលពីមុនៗ ក៏អាចមើលឃើញពីការចូលរួមយ៉ាងសកម្ម និងគាំទ្រយ៉ាងពេញលេញពីសំណាក់សង្គមស៊ីវិល តាមរយៈវេទិកាស្វ័យភាព និងការរៀបចំឡើងដោយខ្លួនឯង។ ទោះជាយ៉ាងណាក្តី កិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារនៅក្នុងឆ្នាំ ២០២១ មិនបានទទួលអាណត្តិណាមួយពីសេចក្តីសម្រេច ឬដំណើរការនៃអន្តររដ្ឋាភិបាលណាមួយនោះទេ។ ផ្ទុយទៅវិញ វាជាការសម្រេច ចិត្តរបស់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិដែលឆ្លើយតបទៅនឹងសំណើរបស់វេទិកាសេដ្ឋកិច្ចពិភពលោក (WEF) ដែលជាអង្គការវិស័យឯកជន តំណាងឱ្យផលប្រយោជន៍ក្រុមហ៊ុនសាជីវកម្មសកលលោកតែប៉ុណ្ណោះ។ សេចក្តីសម្រេចនេះ ទទួលបានការគាំទ្រពីរដ្ឋជាសមាជិកដែលមានអំណាចមួយចំនួនតូច និងក្រុមម្ចាស់មូលនិធិដែលចូលរួមក្នុងការងារសង្គមដើម្បីបន្តជំរុញផលប្រយោជន៍របស់ក្រុមមូលធន (philanthro-capitalist) ធំៗមួយចំនួន ក្នុងនាមជាអ្នកឧបត្ថម្ភកិច្ចប្រជុំកំពូលនេះ។

បើទោះបីជា អគ្គលេខាធិការនៃកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារលើកឡើងថា កិច្ចប្រជុំកំពូលឆ្នាំ ២០២១នេះ "ជាកិច្ចប្រជុំកំពូលមានលក្ខណៈបើកចំហបំផុតមិនដែលធ្លាប់មានពីមុន"មកក្តី ការដឹកនាំកិច្ចប្រជុំកំពូលនេះ នៅតែស្ថិតក្នុងកណ្តាប់ដៃរបស់ក្រុមហ៊ុនសាជីវកម្មចម្រុះជាតិសាសន៍ធំៗដដែល។ "អ្នកជំនាញ" ដែលគេស្គាល់ថា ជាអ្នកការពារវិស័យកសិឧស្សាហកម្មដ៏រឹងមាំ និងប្រទេសមហាអំណាចមួយចំនួន ដែលមានក្រុមហ៊ុនសាជីវកម្មអន្តរជាតិធំៗទាំងនេះ ត្រូវបានគេមើលឃើញថាកំពុងតែដឹកនាំរបៀបវារៈនៃកិច្ចប្រជុំកំពូលនេះ។

ចលនាសង្គម ត្រូវបានរឹតត្បិតមកជាដំណើរការកិច្ចសន្ទនាក្រៅកិច្ចប្រជុំផ្លូវការជំនួសវិញ ហើយពួកយើងក៏មិនអាចចូលរួមដោយស្វ័យភាពបាននោះទេ។ អគ្គលេខាធិការនៃកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារ មានចេតនាមិនទាក់ទងចលនា ឬវេទិកាសង្គមដែលមានស្រាប់ ដូចជាចលនាឡាវៀខែមប៉េះស៊ីណា (LVC) ឬ គណៈកម្មាធិការអាយភីស៊ី (IPC)។ ផ្ទុយទៅវិញ អគ្គលេខាធិការដ្ឋានបែរជាធ្វើការសម្រេចជ្រើសរើសអ្នកចូលរួមមកពីអង្គការផ្សេងៗទៅវិញ។ អង្គការ និងរូបវន្តបុគ្គលមួយចំនួនតូច ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងអង្គភាពប្រឹក្សាយោបល់ ខណៈការអញ្ជើញអោយចូលរួមជាលក្ខណៈបុគ្គលមានការកើនឡើងកាន់តែច្រើនក្នុងនាមជា "បុគ្គលឆ្នើម" នៅក្នុងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារ។ មិនមានសញ្ញាណណាមួយ បើកអោយអ្នកផលិតអាហារ ឬកសិករខ្នាតតូច សង្គមស៊ីវិល និងអង្គការជនជាតិដើមភាគតិចចូលរួមប្រកបដោយគោរពស្វ័យភាព ការចាត់ចែងដោយខ្លួនឯង និងស្វ័យសម្រេចនោះឡើយ។

នៅខែតុលា ឆ្នាំ ២០២០ យន្តការសង្គមស៊ីវិល បានអំពាវនាវជាចំហឱ្យមានការចូលរួមក្នុងការឆ្លើយតបនឹងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារ ដោយមានការប្រកាសថ្កោលទោសការមិនដាក់បញ្ចូល និងអញ្ជើញចលនាសង្គម និងអង្គការនានាដែលធ្វើការពាក់ព័ន្ធនឹងស្បៀងអាហារ ចូលរួមប្រមូលផ្តុំគ្នាបង្កើតជាដំណើរការរួមគ្នាមួយដើម្បីប្រឆាំងតវ៉ានឹងកិច្ចប្រជុំកំពូលនេះ។ មួយខែក្រោយមកបន្ទាប់ពីការអំពាវចូលរួមសកម្មភាពនេះ និងជិតមួយឆ្នាំបន្ទាប់ពីការប្រកាសអំពីការរៀបចំកិច្ចប្រជុំកំពូលនេះ ដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ប្រធានគណៈកម្មាធិ-ការសន្តិសុខស្បៀងអាហារពិភពលោក ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគណៈកម្មាធិការប្រឹក្សាយោបល់។ ដំណាលគ្នានោះដែរក៏មានការអញ្ជើញឱ្យចូលរួម ដោយយន្តការសង្គមស៊ីវិល នៅក្នុងកិច្ចពិភាក្សា "បណ្តុំសកម្មភាព" ដែលជាកិច្ចពិភាក្សាពិគ្រោះយោបល់ក្នុងចំណោមភាគីពាក់ព័ន្ធនឹងកម្មវត្ថុជាច្រើននៃកិច្ចប្រជុំកំពូលនេះ។

ក្រៅពីភាពឃើតយ៉ាវនៃការអញ្ជើញចូលរួមទាំងនេះ តួនាទីរបស់គណៈកម្មាធិការសន្តិសុខស្បៀងអាហារពិភពលោក ក្នុងនាមជាវេទិកាគោលនយោបាយអន្តរជាតិ និងអន្តររដ្ឋាភិបាលនាំមុខ (និងអង្គការស្បៀងអាហារ និងកសិកម្មដែលជាទីភ្នាក់ងារអនុវត្តសំខាន់) ទៅលើបញ្ហាស្បៀងអាហារបន្តចុះខ្សោយទៅៗ។ គំនិតដែលថា កិច្ចពិភាក្សាត្រូវកម្រិតមកត្រឹមជាលក្ខណៈ “អ្នកជំនាញការ” ក្នុងការដឹកនាំធ្វើគោលនយោបាយប្រព័ន្ធស្បៀងអាហារសកល គឺមិនមានលក្ខណៈប្រជាធិបតេយ្យទាល់តែសោះ។ គំនិតទាំងនោះត្រូវបានគេច្រានចោលជាឯកច្ឆន្ទ និងជំនួសដោយកំណែទម្រង់គណៈកម្មាធិការសន្តិសុខស្បៀងអាហារ។ គន្លងបច្ចុប្បន្ននៃដំណើរការរៀបចំកិច្ចប្រជុំកំពូលនេះបើក ឱកាសឱ្យប្រទេសមហាអំណាច និងជាពិសេសវិស័យឯកជន មានភាពស្របច្បាប់ និងអាចគូសវាសអនាគតនៃប្រព័ន្ធស្បៀងអាហាររបស់ពួកយើង ក្រោមរូបភាពផ្សេងៗដែលក្រុមហ៊ុនសាជីវកម្មចម្រុះជាតិសាសន៍អាចបន្តស្រូបយកមូលធន និងបំផ្លិចបំផ្លាញភពផែនដី។

និយាយរួម វាកំពុងតែផ្តល់ឱកាសឱ្យក្រុមហ៊ុនកសិពាណិជ្ជកម្មមានសិទ្ធិដែលឥតព្រំដែន ក្នុងការកំណត់នូវអនាគតនៃប្រព័ន្ធស្បៀងអាហាររបស់ពួកយើង ដោយគ្របដណ្តប់ដោយគោលនយោបាយសាធារណៈ ប្រឆាំងទៅនឹងគោលការណ៍ប្រជាធិបតេយ្យ។ ហេតុដូច្នេះ ពួកយើងមិនអាចទទួលស្គាល់កិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារនៅក្នុងឆ្នាំ ២០២១នេះ ថាជាវេទិការដ្ឋាភិបាលពហុភាគីស្របច្បាប់មួយ ដែលអនុញ្ញាតឱ្យមានការចូលរួមស្វ័យភាពពីសំណាក់សង្គមស៊ីវិលនោះទេ។ ដំណើរការទាក់ទងនឹងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារនេះ ក៏បានបង្ហាញយ៉ាងច្បាស់ពីការកើនឡើងនូវការជ្រៀតជ្រែកពីសំណាក់ក្រុមហ៊ុនសាជីវកម្មនៅក្នុងស្ថាប័នអង្គការសហប្រជាជាតិសំខាន់ៗមួយចំនួន។




by Polyp (Permission for use issued to La Via Campesina in 2018)
More at www.polyp.org.uk

# ពួកយើងចង់បានគោលនយោបាយស្បៀងអាហារដែលមិនមានការជ្រៀតជ្រែកពីក្រុមហ៊ុនសាជីវកម្ម

ច្រើនជាង ២ ទសវត្សមកនេះ ចលនាឡាវៀខែមប៉េះស៊ីណា (LVC) រួមជាមួយនឹងចលនាសង្គមផ្សេងទៀត និងអង្គការសង្គមស៊ីវិល បានលាតត្រដាងពីហានិភ័យនៃការគ្រប់គ្រងពីសំណាក់ក្រុមហ៊ុនសាជីវកម្មទៅក្នុងប្រព័ន្ធស្បៀងនៅគ្រប់កម្រិត។[2] នៅពេលនេះ ពួកយើងសម្តែងការព្រួយបារម្ភរបស់ពួកយើងទៅលើដំណើរការនានាពាក់ព័ន្ធទៅនឹងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារនៅក្នុងឆ្នាំ ២០២១។ មានការចង្អុលបង្ហាញយ៉ាងច្បាស់ថា ផលប្រយោជន៍របស់ក្រុមហ៊ុនសាជីវកម្ម នឹងត្រូវបានគ្របដណ្តប់នៅក្នុងកិច្ចប្រជុំកំពូលនេះ ជាមួយភស្តុតាងបង្ហាញចេញយ៉ាងច្បាស់ថា កិច្ចប្រជុំកំពូលនេះ កើតឡើងចេញពីភាពជាដៃគូរវាងវេទិកាសេដ្ឋកិច្ចពិភពលោក និងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

ការព្រួយបារម្ភទាំងនេះ ត្រូវបានបញ្ជាក់កាន់តែច្បាស់បន្ថែមទៀតនៅក្នុងកិច្ចសន្ទនារបស់ពួកយើង ជាមួយនឹងបេសកជនពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវបានតែងតាំងសម្រាប់ការត្រួតពិនិត្យលើកិច្ចប្រជុំកំពូល គឺលោកស្រីបណ្ឌិត អេគនេស កាលីបាតា (Agnes Kalibata)។ បច្ចុប្បន្ន លោកស្រីបណ្ឌិត គឺជានាយកនៃសម្ព័ន្ធដើម្បីបដិវត្តបៃតងនៅក្នុងទ្វីបអាហ្រ្វិក ឬហៅកាត់ជាភាសារអង់គ្លេសសម្ព័ន្ធអាក្រា (AGRA) ដែលជាស្ថាប័នមួយពោរពេញដោយបញ្ហាជាច្រើនក្នុងចំណោមចលនាសង្គម និងសង្គមស៊ីវិលនៅអាហ្រ្វិក និងតំបន់ផ្សេងទៀត ចាប់តាំងពីពេលបង្កើតស្ថាប័ននោះមកម្ល៉េះ។

រឿងរ៉ាវនាពេលថ្មីៗនេះនៅក្នុងអាហ្វ្រិក បានលាតត្រដាងនូវមហន្តរាយពីភាពបរាជ័យនៃផែនការបញ្ចប់ភាពអត់ឃ្លាន ទូទាំងទ្វីបអាហ្រ្វិករបស់សម្ព័ន្ធបដិវត្តបៃតង សម្ព័ន្ធអាក្រា (AGRA) តាមរយៈការផ្លាស់ប្តូរយ៉ាងគំហុកនៃប្រព័ន្ធកសិកម្មរបស់ទ្វីបអាហ្រ្វិក ឆ្ពោះទៅរកឧស្សាហកម្ម និងគំរូកសិកម្មដែលពឹងផ្អែកទៅលើសារធាតុគីមី។ នៅក្នុងកែវភ្នែករបស់ពួកយើង ការតែងតាំងលោកស្រីបណ្ឌិត អេគនេស កាលីបាតា (Agnes Kalibata) ជាបេសកជនពិសេសសម្រាប់កិច្ចប្រជុំកំពូលនេះ បង្ហាញពីទំនាក់ទំនងនៃការជម្រុញផលប្រយោជន៍របស់ក្រុមហ៊ុនសាជីវកម្មចម្រុះជាតិសាសន៍ ក្នុងការប៉ុនប៉ងពង្រីកការត្រួតត្រាទៅលើ "កិច្ចប្រជុំកំពូលនេះ" ហើយដោយព្យាយាមបន្តពង្រីកអំណាចរបស់ខ្លួនទៅលើគោលនយោបាយសាធារណៈ និងអភិបាលកិច្ចនៃប្រព័ន្ធស្បៀងអាហារសកលលោក។

ពួកយើងជឿជាក់ថា វាជាការសំខាន់ណាស់ក្នុងការប្រឆាំងតវ៉ាទៅនឹងការជ្រៀតជ្រែកពីក្រុមហ៊ុនសាជីវកម្មទៅលើប្រព័ន្ធស្បៀងអាហារដោយហេតុថា ក្រុមហ៊ុនកសិពាណិជ្ជកម្មសកលលោកគាំទ្រការដាក់បញ្ចូលនូវគំរូបែបហិរញ្ញវត្ថុ ទីផ្សារទៅក្នុងផលិតកម្ម និងការចែកចាយស្បៀងអាហារ។ មូលហេតុនេះហើយដែលបង្កើតឱ្យមានវិបត្តិស្បៀងអាហារកាលពីឆ្នាំ ២០០៨ និងបន្តផ្តល់ផលប៉ះពាល់ជាលក្ខណៈអវិជ្ជមានដល់អ្នកផលិត កសិករខ្នាតតូច និងប្រជាជនទូទៅនៅទូទាំងពិភពលោក។ នាពេលបច្ចុប្បន្ន ក្រុមហ៊ុនសាជីវកម្មមួយចំនួនតូច មានគោលបំណងគ្រប់គ្រងទិន្នន័យទៅលើដីកសិកម្ម ទឹក គ្រាប់ពូជ និងធនធានផ្សេងទៀត ដោយសារវិធីនេះ នឹងធ្វើឱ្យពួកគេឈានដល់ការគ្រប់គ្រងទៅលើប្រព័ន្ធស្បៀងអាហាររបស់ពួកយើង ដើម្បីតែ

2 https://viacampesina.org/en/ending-corporate-capture-of-the-united-nations/ and https://www. eurovia.org/la-via-campesina-issues-call-to-mobilise-against-wto-and-free-trade-agreements/




ផលប្រយោជន៍ឯកជន និងការត្រួតត្រាពិភពលោក។ ការអនុវត្តបែបបំផ្លិចបំផ្លាញរបស់ពួកគេ ដោយរួមមានការរំលោភបំពានជាទ្រង់ទ្រាយធំ ការក្ដោបយកនិងការធ្វើឯកជនភាវូបនីយកម្មលើដីធ្លី ទឹក និងធនធានផ្សេងទៀត ហើយនឹងការធ្វើឧស្សាហនីយកម្មលើវិស័យកសិកម្ម ការនេសាទ និងការចិញ្ចឹមសត្វ ការកេងប្រវ័ញ្ចហួសហេតុទៅលើធនធានធម្មជាតិ (រួមទាំងការកេងប្រវ័ញ្ចលើមនុស្ស) ភាពអាណាធិបតេយ្យ និងមហិច្ឆតា នៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីដើម្បីគ្រប់គ្រងពិភពលោក និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដោយពឹងផ្អែកលើការវិនិយោគផ្ទាល់ពីបរទេស និងបំណុលសាធារណៈដែលគ្មាននិរន្តរភាព។

ការជ្រៀតជ្រែកពីក្រុមហ៊ុនសាជីវកម្ម កំពុងតែបានពង្រីកវិសាលភាពនៅក្នុងវេទិកាគោលនយោបាយថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ហើយបន្តព្យាយាមបង្កើនឥទ្ធិពលរបស់ខ្លួននៅក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ។ កិច្ចព្រមព្រៀងភាពជាដៃគូរវាងវេទិកាសេដ្ឋកិច្ចពិភពលោក និងអង្គការសហប្រជាជាតិ ដែលបានចុះហត្ថលេខានៅឆ្នាំ ២០១៩ ជាការផ្ដល់នូវការជ្រៀតចូលបែបអនុគ្រោះ និងលើកទឹកចិត្តដល់ក្រុមហ៊ុនសាជីវកម្មចម្រុះជាតិសាសន៍ទៅក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ។ ភាពជាដៃគូនេះ ត្រូវបានចលនាឡាវៀខែមប៉េះស៊ីណា (LVC) និងអង្គការផ្សេងទៀត ធ្វើការប្រកាសថ្កោលទោស ដោយលើកឡើងនៅក្ដីព្រួយបារម្ភចំពោះផលប៉ះពាល់ដ៏ធ្ងន់ធ្ងររបស់វាទៅលើបូរណភាពរបស់អង្គការ សហប្រជាជាតិក្នុងនាមជាប្រព័ន្ធពហុភាគីមួយដែលមានឯករាជ្យភាព និងអព្យាក្រិត ជាពិសេសពាក់ព័ន្ធនឹងការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស។ លើសពីនេះ ទីភ្នាក់ងារជាច្រើនរបស់អង្គការសហប្រជាជាតិ រួមទាំងអង្គការយូនីសេហ្វ (UNICEF), កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP), អង្គការសុខភាពពិភពលោក (WHO) និង អង្គការយូណេស្កូ (UNESCO) បានចូលរួមក្នុងភាពជាដៃគូជាមួយនឹងបណ្ដាក្រុមហ៊ុនអន្តរជាតិធំៗ ហើយទន្ទឹមនឹងនេះ ទីភ្នាក់ងារទាំងនេះមិនបានទប់ស្កាត់ឱ្យបានគ្រប់គ្រាន់អំពីនិទណ្ឌភាពរបស់ក្រុមហ៊ុនអន្តរជាតិទាំងនោះឡើយ។ ជាលទ្ធផល យើងមើលឃើញថា មានគោលនយោបាយរបស់អង្គការសហប្រជាជាតិកាន់តែច្រើនឡើងៗ បម្រើឱ្យផលប្រយោជន៍ឯកជន និងការឆក់ឱកាសរបស់ពួកគេ ជាជាងការគិតគូរពីផលប្រយោជន៍សាធារណៈ។

## ពួកយើងការពារចំណេះដឹងរួមនៃប្រព័ន្ធស្បៀងអាហារ

កិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីស្បៀងអាហារ ត្រូវបានប្តូរឈ្មោះទៅជាកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីពីប្រព័ន្ធស្បៀងអាហារ ដោយនៅក្នុងការអះអាងជាថ្មីហើយជឿជាក់ថា ការផ្លាស់ប្តូរនេះនឹងភ្ជាប់ជាមួយនូវ "ការដោះស្រាយបញ្ហាភាពអត់ឃ្លាន និងកាត់បន្ថយបញ្ហាជម្ងឺពាក់ព័ន្ធនឹងរបបអាហារ ព្រមទាំងព្យាបាលភពផែនដីផង"។ ខណៈដែលការផ្លាស់ប្តូរទៅជា "ប្រព័ន្ធស្បៀងអាហារ" គឺជាជំហានមួយដែលចេញពីគំរូ "សន្តិសុខស្បៀង" ដែលលេចធ្លោនៅក្នុងស្ថាប័នរបស់អង្គការសហប្រជាជាតិ នៅពេលដែលរាល់សញ្ញាណទាំងអស់ត្រូវបានបង្ហាញថា ប្រព័ន្ធស្បៀងអាហារ នឹងបន្តកំណត់ឡើងបែរសម្រួលដល់ឥទ្ធិពលនៃការត្រួតត្រាពីក្រុមហ៊ុនសាជីវកម្មដដែល។

នៅក្នុងដំណើរការស្របពេលគ្នា និងកំពុងបន្តនៅក្នុងគណៈកម្មាធិការសន្តិសុខស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ (CFS) ជាពិសេសដំណើរការចរចាលើគោលការណ៍ណែនាំស្ម័គ្រចិត្តអំពីប្រព័ន្ធស្បៀង និងអាហាររូបត្ថម្ភ មានការជម្រុញការយល់ដឹងអំពីប្រព័ន្ធស្បៀងអាហារកាន់តែចង្អៀត ហើយវិស័យឯកជននៅតែបានបន្តអនុញ្ញាតឱ្យទទួលយកភារកិច្ចក្នុងការផ្លាស់ប្តូរប្រព័ន្ធមួយនេះ។ ស្ថាប័នអង្គការសហប្រជាជាតិ បន្តទាញយកនិយមន័យជាច្រើនពីអ្នកតាក់តែងគោលនយោបាយដែលគ្មានបទពិសោធន៍ទៅលើប្រព័ន្ធស្បៀងអាហារពិតប្រាកដ ដែលនាំឱ្យប្រព័ន្ធស្បៀងអាហារត្រូវបានគេយល់ត្រឹមតែលើសមិទ្ធិផលមើលឃើញចុងក្រោយរបស់ពួកគេ គឺតាមរយៈ៖ ការដាក់ម្ហូបនៅលើចាន។

ចលនាទ្បាវៀខែមប៉េះស៊ីណា (LVC) បានបន្តជម្រុញអ្នកតាក់តែងគោលនយោបាយដែលធ្វើការនៅក្នុងស្ថាប័នអង្គការសហប្រជាជាតិឱ្យមានចក្ខុវិស័យទូលាយទៅលើប្រព័ន្ធស្បៀងអាហារ។ វាជាការសំខាន់ដែលត្រូវចងចាំថា នៅខណៈដែលទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ កំពុងតែពិភាក្សា ថាតើពួកគាត់ត្រូវការប្រព័ន្ធស្បៀងអាហារមួយដែរឬទេ ហើយប្រព័ន្ធស្បៀងអាហារជាអ្វី ហើយថាតើពួកគាត់ត្រូវកែប្រែប្រព័ន្ធស្បៀងអាហារនោះឬយ៉ាងណា។ ចលនាទ្បាវៀខែមប៉េះស៊ីណា (LVC) បានតស៊ូមតិលើទស្សនៈអធិបតេយ្យស្បៀងដែលជាចក្ខុវិស័យមូលដ្ឋានច្បាស់លាស់នៃការផ្លាស់ប្តូរប្រព័ន្ធស្បៀងអាហារចាប់តាំងពីឆ្នាំ ១៩៩៤ មកម្ល៉េះ។ ខណៈដែលមានការទទួលស្គាល់កាន់តែច្រើនឡើងថាឧស្សាហកម្មភាវូបនីយកម្ម និងការបង្កើនផលិតកម្មស្បៀងអាហារនាប៉ុន្មានសតវត្សចុងក្រោយនេះ បានបណ្តាលឱ្យមានការខូចខាតប្រព័ន្ធអេកូឡូស៊ី ការបណ្តេញចេញប្រជាពលរដ្ឋពីលំនៅដ្ឋាន កាកសំណល់ម្ហូបអាហារ និងការបរិភោគអាហារមិនមានសុខភាពល្អ និងគ្មាននិរន្តរភាពនៅតែបន្ត រួមទាំងការមិនយកចិត្តទុកដាក់ ក្នុងការកំណត់រកអ្នកទទួលខុសត្រូវទៅលើបញ្ហាទាំងអស់នេះ៖ ហើយបញ្ហាទាំងនេះ មានទំនាក់ទំនងជាមួយគោលនយោបាយកសិពាណិជ្ជកម្ម និងគោលនយោបាយជម្រុញផលិតភាពកសិកម្ម។

## តើប្រព័ន្ធស្បៀងអាហារបែបណាដែលពួកយើងត្រូវការ?

ពួកយើងជឿជាក់ថា គ្មានការផ្លាស់ប្តូរជាលក្ខណៈប្រព័ន្ធណាមួយអាចធ្វើទៅបានតាមរយៈការរឹតត្បិតការចូលរួម និងបង្កើនឥទ្ធិពលត្រួតត្រាដល់ក្រុមហ៊ុនសាជីវកម្ម និងការបំផ្លិចបំផ្លាញធម្មជាតិនោះទេ។ វិធីសាស្ត្រទាំងអស់នេះ ត្រូវបានបរាជ័យជាច្រើនដងច្រើនសាររួចមកហើយ។ អ្នកស្រែ អ្នកនេសាទ ជនជាតិដើមភាគតិច អ្នកចិញ្ចឹមសត្វ អ្នកស្រុកព្រៃ កម្មករក្នុងវិស័យកសិកម្ម ក៏ដូចជាអ្នកប្រើប្រាស់នៅក្នុងទីក្រុង និងជនបទ គឺជាបេះដូងនៃប្រព័ន្ធស្បៀងអាហារ។

សម្លេងពីក្រុមមនុស្សទាំងនេះ ត្រូវតែដាក់បញ្ចូលឱ្យបានលឺនៅក្នុងអង្គការសហប្រជាជាតិ ប្រសិនបើចង់សម្រេចបាននូវការផ្លាស់ប្តូរ ហើយប្រសិនបើអង្គការសហប្រជាជាតិជាវេទិកាមួយ ជម្រុញឱ្យមានការកែប្រែប្រព័ន្ធស្បៀងអាហារពិតប្រាកដ។ប្រព័ន្ធស្បៀងអាហារ នឹងមិនមាននិរន្តរភាព ព្រមទាំងមិនប្រកបដោយសមធម៌នោះឡើយ ប្រសិនបើអង្គការសហប្រជាជាតិ នៅតែបន្តពឹងផ្អែកលើសម្លេងរបស់ក្រុមហ៊ុនសាជីវកម្ម អ្នកស្រាវជ្រាវដែលទទួលការឧបត្ថម្ភគាំទ្រ និងអ្នកបង្កើតគោលនយោបាយរបស់ប្រទេសមហាអំណាចទាំងនោះ។

ដើម្បីសម្រេចបាននូវការផ្លាស់ប្តូរប្រព័ន្ធស្បៀងអាហារមួយក្នុងបរិបទនេះ ពួកយើងទាមទារដូចខាងក្រោម ៖

- បង្កើតប្រព័ន្ធស្បៀងអាហារក្នុងស្រុកដោយប្រជាពលរដ្ឋដែលមានលក្ខណៈចម្រុះ និងការអនុវត្តកសិត្របរិស្ថានជាជាងការបង្កើតឡើងវិញ និងការពង្រីកប្រព័ន្ធស្បៀងអាហារជាលក្ខណៈសកលលោក តាមទម្រង់របស់ក្រុមហ៊ុនសាជីវកម្ម។ បង្កើតឱ្យមានកំណែទម្រង់ដីកសិកម្មពិតប្រាកដ ឱ្យបានច្រើនប្រទេស ហើយធ្វើការគាំទ្រនិងលើកកម្ពស់គ្រាប់ពូជក្នុងស្រុក។
- ធ្វើការផ្លាស់ប្តូរជាប្រព័ន្ធ ដើម្បីដោះស្រាយវិបត្តិបំរែបំរួលអាកាសធាតុនាពេលបច្ចុប្បន្ន និងសម្រេចបានការកាត់បន្ថយការសាយភាយនៃឧស្ម័នកាបូនិក និងទទួលស្គាល់ថា កសិកម្មបែបឧស្សាហកម្ម និងប្រព័ន្ធស្បៀងអាហារដោយក្រុមហ៊ុនសាជីវកម្មបច្ចុប្បន្នកំពុងតែបង្កនូវវិបត្តិទាំងនេះ។
- កែប្រែគោលនយោបាយពាណិជ្ជកម្មដែលមានស្រាប់ ឱ្យមានលក្ខណៈគាំទ្រ និងការពារផលិតកម្មស្បៀងអាហារក្នុងស្រុក។
- លើកកម្ពស់គោលនយោបាយសាធារណៈប្រកបដោយប្រសិទ្ធភាពនៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងក្នុងស្រុក ដែលនឹងពង្រឹងផលិតកម្មរបស់កសិករខ្នាតតូច អ្នកស្រែ ក្នុងគោលការណ៍កសិត្របរិស្ថាន និងការពារទីផ្សារក្នុងស្រុក។
- ធានាការអនុវត្តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិអ្នកស្រែ និងប្រជាជនដទៃទៀតដែលប្រកបរបរនៅតំបន់ជនបទ (UNDROP) គ្រប់លំដាប់ថ្នាក់ ថាជាលិខិតតូបករណ៍សំខាន់មួយសម្រាប់ការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស និងសិទ្ធិការងារ។

នៅខណៈដែលពិភពលោក កំពុងតែវិលវល់ជាមួយជម្ងឺរាតត្បាត និងបន្តទទួលរងផលវិបាកពីវិបត្តិអាកាសធាតុ ចលនាឡាវៀខែមប៉េះស៊ីណា (LVC) ជម្រុញឱ្យរដ្ឋាភិបាលនានានៃអង្គការសហប្រជាជាតិ លើកយករបៀបវារៈនៃការធ្វើកំណែទម្រង់សង្គមមកពិភាក្សា។ ចំណុចស្នូលដែលត្រូវយកមកពិភាក្សាក្នុងកំណែទម្រង់សង្គមនេះ គឺការផ្តោតសំខាន់ទៅលើផលិតកម្មស្បៀងអាហារក្នុងស្រុក និងប្រព័ន្ធស្បៀងអាហារក្នុងស្រុក ការឈានទៅរកថាមពលកកើតឡើងវិញ និងពង្រឹងវិស័យសាធារណៈ។ អ្នកតំណាងចលនាសកលធំៗ និងអង្គការនានាត្រូវដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើតគំនិតផ្តួចផ្តើមទាំងអស់នេះ។




ចលនាឡាវៀខែមប៉េះស៊ីណា (LVC) ជាសម្លេងរបស់អ្នកផលិតអាហារអ្នកស្រែច្រើនជាង ២០០ លាននាក់ មានការជឿជាក់យ៉ាងច្បាស់ថា មានតែប្រព័ន្ធស្បៀងអាហារដែលមានភាពសុខដុមជាមួយនឹងធម្មជាតិ និងគោរពសិទ្ធិមនុស្សតែមួយគត់ ដែលអាចការពារអាយុជីវិត សន្តិភាព និងសុខមាលភាពប្រជាពលរដ្ឋ និងប្រជាជនជំនាន់ក្រោយទៀតបាន។

អធិបតេយ្យស្បៀង គឺជាត្រីវិស័យរបស់ពួកយើងទាំងអស់គ្នា ហើយការឈានទៅរកក្សេត្របរិស្ថាន គឺជាផែនទីរបស់យើងសម្រាប់ធ្វើដំណើរឆ្ពោះទៅរកកំណែទម្រង់ជាលក្ខណៈប្រព័ន្ធដែលពួកយើងត្រូវការ។




**សម្រាប់ព័ត៌មានបន្ថែម៖**

គេហទំព័រ៖ **www.viacampesina.org/en**

បណ្ដាញព័ត៌មានសង្គម ហ្វេសប៊ុក៖ **facebook.com/ViaCampesinaOfficial**

បណ្ដាញធ្វីតធើ៖ **@via_campesina**